# របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិ ទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆមាសទី២ ឆ្នាំ២០១៩

**កិច្ចប្រជុំពេញអង្គលើកទី២**
**ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩**

**ឯកឧត្តម ឈឹម យិនដារ៉េត**
**អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# មាតិកា

១- វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំ សម្របសម្រួល និងចលនាប្រភពធនធាន

២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍

៣. វឌ្ឍនភាព និងសមិទ្ធផលនៃការថែទាំ និងព្យាបាល

៤. វឌ្ឍនភាព និងសមិទ្ធផលនៃការកាត់បន្ថយផលប៉ះពាល់ និងការរើសអើង

៥. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្កើនបរិយាកាសគាំទ្រការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍

៦- វឌ្ឍនភាព និងសមិទ្ធផលនៃការតាមដាន និងវាយតម្លៃ

៧. សេចក្តីសន្និដ្ឋាន

៨. សេចក្តីថ្លែងអំណរគុណ

# ១. វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំ សម្របសម្រួល និងចលនាប្រភពធនធាន

- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំស្តីពីការអង្គាសថវិកា លើកទី៦ របស់មូលនិធិសកល (6th Replenishment of GFATM) នៅទីក្រុងលីយ៉ុង ប្រទេសបារាំង ពីថ្ងៃទី៩ដល់១០ ខែតុលា ឆ្នាំ២០១៩។ ជាលទ្ធផល សន្និសីទអង្គាសថវិកាបានចំនួន ១៤,០២ប៊ីលានដុល្លារសហរដ្ឋអាមេរិក។

- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានចូលរួមបើកសិក្ខាសាលាស្តីពីការជជែកពិភាក្សាលើកកម្ពស់ក្មេងស្រីដើម្បីអានាគតភ្លឺស្វាង (Girls Act) នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ដើម្បីលើកកម្ពស់បំណិនជីវិតក្នុងការការពារការឆ្លងមេរោគអេដស៍ និងការបំពានរាងកាយផ្លូវភេទ។








- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជួបពិភាក្សាការងារជាមួយតំណាង UNAIDS ស្តីពីការត្រៀមរៀបចំកិច្ចប្រជុំក្នុងការពន្លឿន (Fast-tract cities) ការឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍នៃទីក្រុងប្រទេសនិយាយភាសាបារាំង។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី៤ ជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តប្រឈមមុខខ្ពស់ (សៀមរាប ព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ កំពត និងរាជធានីភ្នំពេញ)។

# ១. វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំ សម្របសម្រួល និងចលនាប្រភពធនធាន (ត)

- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំដើម្បីពិនិត្យ ពិភាក្សាលើផែនការសកម្មភាព និងផែនការថវិកា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២០។

- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ**ការអង្កេតសន្ទស្សន៍ការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍២.០** នៅប្រទេសកម្ពុជា នាសណ្ឋាគារភ្នំពេញ។ សិក្ខាសាលានេះរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការFHI360, Linkages, Population Council និងCPN+ និងទទួលការឧបត្ថម្ភពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) PEPFAR និង UNAIDS។









- ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានចូលរួមបើកកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី**របកគំហើញនៃការវាយតម្លៃអំពីគោលនយោបាយ និងផ្លូវច្បាប់ក្នុងការទទួលបានសេវាសុខភាព សេវាព្យាបាលមេរោគអេដស៍ និងសេវាសង្គមសម្រាប់ក្រុមបុរសស្រឡាញ់បុរសដូចគ្នា** នាសណ្ឋាគារហ៊ីម៉ាវ៉ារី។ រៀបចំដោយអង្គការ KHANA អង្គការ UNAIDS។

# ១. វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំ សម្របសម្រួល និងចលនាប្រភពធនធាន (ត)

- ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៩ ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាពហុវិស័យរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍**ខេត្តកំពង់ចាម ត្បូងឃ្មុំ និងស្វាយរៀង**ប្រចាំឆមាសទី២ ឆ្នាំ២០១៩ ដែលប្រារព្ធធ្វើឡើង នៅមន្ទីរសុខាភិបាលខេត្តនីមួយៗ ដែលមានអ្នកចូលរួមចំនួនប្រមាណ ១៥០នាក់ ដែលជាតំណាងពាក់ព័ន្ធមកពីមន្ទីរសុខាភិបាល អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងអង្គការសង្គមស៊ីវិលផងដែរ។

- ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អមដំណើរដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល អង្គការKHANA អង្គការHP+ អង្គការMHC និង ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីដំណើរការរបស់**គ្លីនិកឈូកស និងមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម**ក្នុងការផ្តល់សេវាដល់អ្នកជំងឺអេដស៍។







# ១. វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំ សម្របសម្រួល និងចលនាប្រភពធនធាន (ត)

- បានរៀបចំកិច្ចប្រជុំពេញអង្គបានចំនួន២លើក (រួមទាំងលើកនេះ) ស្មើនឹង ១០០%
- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានចំនួន ៩លើក ស្មើនឹង ៨៣%
- បានរៀបចំកិច្ចប្រជុំក្រុមការងារស្តីពីការអនុវត្តសំណើសុំដាក់វិធានការសមស្របអនុវត្តសេចក្តីជូនដំណឹងលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ ជំងឺអេដស៍របស់ទីស្តីការគណៈរដ្ឋមន្ត្រី។







# ១. វឌ្ឍនភាព និងសមិទ្ធផលនៃការដឹកនាំ សម្របសម្រួល និងចលនាប្រភពធនធាន (ត)

ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បើកសិក្ខាសាលាស្តីពីការផ្តល់សុពលភាពលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៩ - ២០២៣ នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់។ NSP V នេះបានឆ្លងកាត់ការប្រជុំពិភាក្សាជាច្រើនលើករបស់ក្រុមការងារ Steering Committee នៅក្នុងកិច្ចប្រជុំនេះមានការចូលរួមពីក្រសួង ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ និងបណ្តាញក្រុមប្រជាជនគន្លឹះ និងតំណាងបណ្តាញអ្នកផ្ទុកមេរោគអេដស៍។



# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអគ្គបញ្ជាការដ្ឋានក្រសួងការពារជាតិ បានយកចិត្តទុកដាក់ អប់រំផ្សព្វផ្សាយស្តីពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងការប្រឈមរបស់យុវវ័យ ដល់នាយទាហាន នាយទាហានរង ពលទាហាន និស្សិតនាយទាហាន ពលនារី កងរាជអាវុធហត្ថ ដែលជាកម្លាំងស្នូលក្នុងការការពារជាតិមាតុភូមិចំនួនប្រមាណ ៣.០០០នាក់។






- ពិធីផ្សព្វផ្សាយ ការស្វែងយល់ពីការបង្ការមេរោគអេដស៍ ដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបុគ្គលិកកម្មករក្រុមហ៊ុនឯកជន EM ផ្នែកបរិក្ខារអគ្គិសនី ដែលនេះជាគំនិតផ្តួចផ្តើមរបស់ក្រុមហ៊ុនផ្ទាល់ក្នុងការថែទាំសុខភាពបុគ្គលិកកម្មកររបស់ក្រុមហ៊ុនប្រមាណ៣០០នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- ក្រសួងបរិស្ថានបានបើកកម្មវិធីផ្សព្វផ្សាយពីការបង្ការការឆ្លងមេរោគអេដស៍ និងការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន ជូនដល់មន្ត្រីរាជការ និងឧទ្យានុរក្ស នៅតាមខេត្តផ្សេងៗដូចជា សៀមរាប កំពត ព្រះសីហនុ និង ព្រះវិហារ ដែលមានសិក្ខាកាមចូលរួមសរុបប្រមាណ៥០០នាក់។






# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)









- បញ្ជ្រាបការអប់រំផ្សព្វផ្សាយការបង្ការ និងទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការកសាងទំនាក់ទំនងរវាងមាតានិងយុវតី ទាក់ទងនឹងសុខភាពបន្តពូជ សុខភាពផ្លូវភេទ នៅខេត្តបាត់ដំបង សរុបចំនួន ៥០ នាក់ (ស្ត្រី ៤៣ នាក់)។
- បញ្ជ្រាបការអប់រំផ្សព្វផ្សាយការបង្ការ និងទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងការរៀបចំវេទិកាអប់រំសហគមន៍ ស្តីពីយេនឌ័រ សុខភាពបន្តពូជ និងអាហារូបត្ថម្ភ ដើម្បីបង្កើនការយល់ដឹងជូនប្រជាជនពលរដ្ឋស្តីពីយេនឌ័រនិងអាហារូបត្ថម្ភ សុខភាពបន្តពូជ និងសិទ្ធិថែទាំសុខភាពក្នុងអំឡុងពេលមានផ្ទៃពោះ មុននិងក្រោយសម្រាល ការបង្ការ និងការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តសៀមរាប បន្ទាយមានជ័យសរុបចំនួនអ្នកចូលរួមទាំងអស់ ៩៣៩នាក់ ស្ត្រី៥៤២នាក់។
- រៀបចំយុទ្ធនាការអប់រំសហគមន៍ស្តីពី យេនឌ័រ សុខភាពបន្តពូជ មេរោគអេដស៍ និងជំងឺអេដស៍ និងអាហារូបត្ថម្ភ នៅខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមចំនួន ៣០៧នាក់ ស្ត្រី១៥៦នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- ចុះតាមដានការអនុវត្តប្រកាសលេខ០៨៦ និងប្រកាសលេខ ១៩៤ និងចុះផ្សព្វផ្សាយបំប៉នសមត្ថភាព យល់ដឹងពីការបង្ការទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍ និងគ្រឿងញៀននិងលក្ខខណ្ឌការងារ វិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្តនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម កំពង់ធំ ព្រះវិហារ ស្វាយរៀង ព្រៃវែង រតនគិរី ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងខេត្តត្បូងឃ្មុំ។
- បានអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ និងផលប៉ះពាល់នៃគ្រឿងញៀនដល់ពលករដែលត្រៀមទៅធ្វើការនៅប្រទេសជប៉ុន សិង្ហបុរី និងហុងកុងចំនួន ៤៧ លើក មានចំនួនសរុប១៥១០ នាក់ ស្រី៥៤៣ នាក់។
- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលដែលជាមន្ត្រីអធិការកិច្ចការងារស្តីពីការកែលម្អរបៀបធ្វើការនៅតាមការដ្ឋានសំណង់ខ្នាតតូច និងបានបញ្ចូលមេរៀនអេដស៍ និងផលប៉ះពាល់នៃគ្រឿងញៀនបានចំនួន៥វគ្គ ស្មើនឹង២៥ រាជធានី-ខេត្ត មានចំនួនសរុប១២១នាក់ ស្រី១៣ នាក់។
- បានធ្វើការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងផលប៉ះពាល់នៃគ្រឿងញៀន ដល់កម្មករនិយោជិតបានចំនួន៣៨ លើកមានចំនួនសរុប ១.៩៨៩ នាក់ ស្រី១.០៩៣ នាក់ ( ខេត្តមណ្ឌលគិរី ប៉ៃលិន ក្រចេះ ស្ទឹងត្រែង កំពង់ធំ កំពង់ស្ពឺ កំពត ព្រះសីហនុ ត្បូងឃ្មុំ បន្ទាយមានជ័យ កោះកុង កណ្តាល សៀមរាប ស្វាយរៀង កោះកុង និងខេត្តប៉ៃលិន )។
- បានបណ្តុះបណ្តាលជនបង្គោល និងមិត្តអប់រំមិត្ត ពីមេរោគអេដស៍ និងគ្រឿងញៀនបានចំនួន០៦លើក មានចំនួនសរុប១៣៦ នាក់ ស្រី៧៧ នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- ផ្សព្វផ្សាយអប់រំ ស្តីពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការបង្ការមេរោគអេដស៍និងជំងឺអេដស៍ និងការបង្ការគ្រោះថ្នាក់ចរាចរណ៍ដល់សិស្សានុសិស្ស យុវជនកាកបាទក្រហម យុវជនកាយឫទ្ធិ និងប្រធានក្រុមប្រឹក្សាយុវជននៅតាមសាលាមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ដោយមានអ្នកចូលរួមសរុបចំនួន ៥១២៤នាក់ ស្រី ២៥៤១នាក់ នៅសាលាប៉ែលធីអន្តរជាតិ ៣សាខា សាលាវេស្ទើន សាលាសុវណ្ណភូមិ សាលាវេស្ទឡាញ វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា នៅរាជធានីភ្នំពេញ ខេត្តស្វាយរៀង ព្រៃវែង មណ្ឌលគិរី ព្រះវិហារ ស្ទឹងត្រែង សាលាគរុកោសល្យភូមិភាគខេត្តតាកែវ និងសាលាគរុកោសល្យភូមិភាគខេត្តកំពង់ចាម។
- បន្តអភិវឌ្ឍខ្លឹមសារមេរៀនសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ព្រមទាំងមេរោគអេដស៍និងជំងឺអេដស៍សម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៧ និងទី១០។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- ក្រសួងបានណែនាំដល់អនុគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីខេត្តទាំង២៥ បន្តកិច្ចខិតខំផ្សព្វផ្សាយដើម្បីការពារទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ដល់បុគ្គលិក និងមន្ត្រីរាជការ និងបុគ្គលិកពាក់ព័ន្ធ។
- បានណែនាំបន្តដោយធ្វើការក្រើនរំឭកដល់អ្នកដែលនៅជុំវិញខ្លួនកុំឱ្យភ្លេចខ្លួនចំពោះមេរោគអេដស៍ និងជំងឺអេដស៍ បានចំនួន៤៥នាក់។
- បានសហការផ្សព្វផ្សាយកិច្ចការពារទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងលើកទឹកចិត្តដល់សមាជិក សមាជិកាអង្គប្រជុំបានចំនួន១លើក បានចំនួន១៣រូប។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)



- បានរៀបចំសិក្ខាសាលាស្វែងរកធាតុចូលក្នុងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ឆ្នាំ២០១៩-២០២៣ លើកទី១ ដែលមានអ្នកចូលរួមចំនួន ៤៤រូប (ស្រី ១៧រូប) ក្នុងនោះសមាសភាពមកពីសមាជិក សមាជិកា គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូពាក់ព័ន្ធនានា។
- បានរៀបចំសិក្ខាសាលា លើកទី២ ស្តីពី រកធាតុចូលលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៩-២០២៣ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមចំនួន ៥០រូប (ស្រី ២៣រូប) ក្នុងនោះសមាសភាពមកពីសមាជិក សមាជិកា គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូពាក់ព័ន្ធនានា។
- បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារឆមាសទី២ ឆ្នាំ២០១៩ និងលើកទិសដៅបន្តឆ្នាំ២០២០ របស់ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានអ្នកចូលរួមសរុបចំនួន៤៥រូប (ស្រី ១៩រូប) ក្នុងនោះសមាសភាពមកពីសមាជិក សមាជិកា គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងអង្គការដៃគូពាក់ព័ន្ធនានា។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)





- សម្តេចកិត្តិព្រឹទ្ធបណ្ឌិតបានអញ្ជើញចុះសួរសុខទុក្ខ សំណេះសំណាលនិងផ្តល់ជំនួយមនុស្សធម៌ដល់ស្ត្រីសម្រាលកូនក្នុងក្នុងមន្ទីរពេទ្យ ដល់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមគ្រួសារនៅតាមផ្ទះ មន្ទីរពេទ្យ និងក្នុងសហគមន៍បាន**១.៨៧២នាក់**
- សម្តេចកិត្តិព្រឹទ្ធបណ្ឌិតបានអញ្ជើញរៀបចំសកម្មភាពផ្សព្វផ្សាយអំពីមេរោគអេដស៍ ជំងឺអេដស៍ដល់ប្រជាពលរដ្ឋក្នុងសហគមន៍សរុប **៤.០៦៣២នាក់**
- បានប្រជុំក្រុមការងារផ្សេងជនធ្វើមថ្នាក់ជាតិចំនួន ៧លើក ដើម្បីរៀបចំផែនការសកម្មភាព ឯកសារគោល និងការផ្សព្វផ្សាយអំពី   មេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០១៩ និងជាពិសេសសកម្មភាពនិងខ្លឹមសារសម្រាប់ទិវាប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានផ្សព្វផ្សាយច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ នៅស្រុកបន្ទាយមាស ខេត្តកំពត ដោយមានអ្នកចូលរួម ៤៣៨នាក់ ស្រី ១៦៨នាក់។
- បានបញ្ជ្រាបការអប់រំពីការយល់ដឹងពាក់ព័ន្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងវេទិកាថ្នាក់ជាតិ បានចំនួន ៦៥ លើក ដោយមានអ្នកចូលរួមសរុប **១៣.៥០០ នាក់**។
- បានបញ្ជ្រាបការអប់រំពីការយល់ដឹងពាក់ព័ន្ធនឹងគោលនយោបាយ សូន្យ បី ដែលរួមមាន កុំឱ្យមានការឆ្លងថ្មី កុំឱ្យមានការរើសអើង និងកុំឱ្យមានការស្លាប់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងគ្រប់កម្មវិធីផ្សព្វផ្សាយច្បាប់របស់ក្រសួង បានចំនួន ១៨ លើក នៅក្នុងក្រុង-ស្រុកចំនួន ១៨ នៃខេត្តចំនួន ៨ រួមមាន ៖ ខេត្តឧត្តរមានជ័យ កែប ព្រៃវែង កំពង់ស្ពឺ កំពត និងខេត្តកំពង់ធំ ដោយមានអ្នកចូលរួមសរុប ៦.៧០៤ នាក់/ស្រី ២.៧០៤ នាក់ ក្នុងនោះ បញ្ជ្រាបតាមរយៈការផ្សព្វផ្សាយ ៖
- -ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន ១០ លើក ដោយមានអ្នកចូលរួម ៣.៦៩៦ នាក់/ស្រី ១.២១១ នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

ក្រសួងទេសចរណ៍
Ministry of Tourism



- បានរៀបចំសិក្ខាសាលាស្តីពីការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់គ្រឿងញៀន នៅខេត្តកំពង់ចាម ពោធិ៍សាត់ និងក្រចេះដែលមានអ្នកចូលរួមទាំងអស់ប្រមាណ ១២០នាក់។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងវិស័យទេសចរណ៍ជូនប្រតិបត្តិករទេសចរណ៍ចំនួន ២៤៦នាក់ (ស្រី១១៧នាក់) រួមមាន ម្ចាស់ឬអ្នកគ្រប់គ្រង បុគ្គលិកមូលដ្ឋានអាជីវកម្ម នារីផ្សព្វផ្សាយស្រាបៀរនៅខេត្តគោលដៅ ដូចជា ខេត្តកែប កំពង់ចាម និងពោធិ៍សាត់ ដែលមានអ្នកចូលរួមទាំងអស់ចំនួន ១១៧នាក់។
- បានចែកចាយ Sticker ផ្សព្វផ្សាយសារស្តីពី សុវត្ថិភាពផ្លូវភេទគឺការប្រើស្រោមអនាម័យ១០០% ចែក ជូនដល់ម្ចាស់សេវាកម្មស្នាក់នៅ ម៉ាស្សា និងខារ៉ាអូខេ ចំនួន៥.០០០សន្លឹក។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានចុះអប់រំផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ជូនកងទ័ព គ្រួសារទ័ពបានចំនួន ២វគ្គ មានអ្នកចូលរួមចំនួន ២៩៥នាក់។
- បានចូលរួមសិក្ខាសាលា ក្រុមប្រឹក្សាបច្ចេកទេស ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែបានចំនួន ៤ លើក នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៣លើក និងនៅសណ្ឋាគារសង្គហាមិត្តគយ ខេត្តកែប ១លើក។
- ការបញ្ជ្រាបការអប់រំស្តីពីមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈកម្មវិធីអប់រំចិត្តសាស្ត្រ កម្មវិធីអប់រំជំងឺគ្រុនចាញ់ កម្មវិធីអប់រំគ្រឿងញៀន ព្រមទាំងកម្មវិធីផ្សេងៗទៅតាមយោធភូមិភាគផ្សេងៗដែលមានពលទាហាន នាយទាហានបានចូលរួមចំនួន ៧.១៨៧នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងបានចូលរួមធ្វើការផ្សព្វផ្សាយ អប់រំ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈវិស័យសាធារណការ និងដឹកជញ្ជូន ដោយសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្តចំនួន ១២ ខេត្ត ដែលមានអ្នកចូលរួមសរុប ៨.០៥៣៥នាក់ ស្រី៣៦១៤៧នាក់។











# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លើកកម្ពស់ការយល់ដឹងមេរោគអេដស៍ ជំងឺអេដស៍ និងឥទ្ធិពលគ្រឿងញៀន បានចំនួន២លើក ដែលមានសមាជិកចូលរួមចំនួន ៣០០នាក់ ស្រី១០០នាក់ ដែលមកពីខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង ប៉ៃលិន កំពង់ស្ពឺ កែប កំពត កោះកុង ព្រះសីហនុ និងតាកែវ។



- បានរៀបចំប្រជុំក្រុមការងារប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងចំនួន២លើក
- បានចូលរួមប្រជុំប្រចាំខែរបស់ក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន២លើក



# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)



- បានរៀបចំកិច្ចប្រជុំពិនិត្យស្ថានភាពការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ នាទីស្ដីការក្រសួង។ អ្នកចូលរួមទាំងអស់ចំនួន ៤១រូប ដែលតំណាងមន្ត្រីរាជការ អ្នកសារព័ត៌មានមកពីអគ្គនាយកដ្ឋានចំនួន៥ ចំណុះឱ្យក្រសួងព័ត៌មាន។
- បានបញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងកម្មវិធីសន្ទនាមតិ នៃវេទិកា ជីវិតយើង សង្គមយើង នៅវិទ្យុជាតិកម្ពុជា។
- បានផលិត និងចាក់ផ្សាយខ្សែវីដេអូអំពីបច្ចុប្បន្នភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)



- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការយល់ដឹងអំពីជំងឺអេដស៍ និងរួមចំណែកទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា នៅភោជនីយដ្ឋានទន្លេបាសាក់២ ។ ក្នុងគោលបំណង ចែករំលែកនូវព័ត៌មាន ចំណេះដឹង និងជំរុញឱ្យមានការយល់ដឹងជាសាធារណៈដល់មន្ត្រីរាជការ និងក្រុមគ្រួសារ សាច់ញាតិ ស្តីពីមូលហេតុ របៀបនៃការចម្លង ផលវិបាក មធ្យោបាយបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ នៅកម្ពុជា។
- បានរៀបចំផ្សព្វផ្សាយគោលនយោបាយថ្មីក្នុងការផ្តល់អត្តសញ្ញាណក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ (PLHIV and KPs) តាមការលើកសំណើ (ID Poor on demand)

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

បានរៀបចំសិក្ខាសាលាស្តីពីការលុបបំបាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ នាថ្ងៃទី ១០-១១ ខែកញ្ញា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ មានអ្នកចូលរួមចំនួន៦០នាក់ដែលជាមន្ត្រីរាជការមកពីក្រសួង។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

បានរៀបចំបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគប្រចាំក្រសួងដែលមានសមាសភាពដូចខាងក្រោម៖









# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

បានសម្របសម្រួលក្នុងការអនុវត្តនូវសេចក្តីជូនដំណឹងលេខ ២១៣សជណ ៖









# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានចូលរួមប្រជុំជាមួយក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានចំនួន២លើក
- បានរៀបចំបើកវគ្គសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការលើកកម្ពស់ការយល់ដឹងពីជំងឺអេដស៍ កាមរោគ និងសុខភាពបន្តពូជ ដល់ប្រជាពលរដ្ឋនៅឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានចំនួន៨៨នាក់ ស្រី៣៩នាក់
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងមានកញ្ចប់ថវិកាជាតិសម្រាប់អនុវត្តសកម្មភាពការងារចំនួន ៨០ លានរៀល ហើយបានប្រើប្រាស់ថវិកានេះអនុវត្តសកម្មភាពបានចំនួន២ដុំ រួចមកហើយក្នុងចំណោមថវិកា៤ដុំ។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានរៀបចំប្រកាសសម្រួលភារកិច្ចថ្មីស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងរ៉ែ និងថាមពល
- បានផ្សព្វផ្សាយចែករំលែកព័ត៌មានតាមរយៈកិច្ចប្រជុំគណៈកម្មាធិការទៅតាមគ្រប់បណ្តាអង្គភាពអគ្គនាយកដ្ឋានចំណុះក្រសួងអំពីការការពារពីជំងឺអេដស៍ និងការប្រើប្រាស់គ្រឿងញៀន។
- បានផ្សព្វផ្សាយតាមរយៈការឆ្លៀតបញ្ចូលក្រៅរបៀបវារៈនៃកម្មវិធីសិក្ខាសាលា និងកិច្ចប្រជុំក្រុមការងារយែនឌ័រ
- បានផ្សព្វផ្សាយបន្ថែមក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់សុខភាពមាតា និងទារក និងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានបញ្ជ្រាបការអប់រំផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈកម្មវិធីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម (សម្តែងធម៌ទេសនា និងផ្សព្វផ្សាយ) បានចំនួន៦លើក ដោយមានថ្នាក់ដឹកនាំក្រសួង មន្ត្រីរាជការ និងអន្តរក្រសួង សិស្ស និស្សិត សីលវន្ត សីលវតី ឧបាសក ឧបាសិកា និងពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានចូលរួមចំនួន១.៩៩៤រូប។
- បានរៀបចំកម្មវិធីទស្សនទានព្រះពុទ្ធសាសនាចំនួន៣លើក ដើម្បីបញ្ជ្រាបនូវចំណេះដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍ដល់សិស្សានុសិស្ស និស្សិត តាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនទូទាំងប្រទេសដោយមានលោកគ្រូ អ្នកគ្រូ ចូលរួមចំនួន ៩.២៤០នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

- បានចូលរួមយ៉ាងទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាបច្ចេកទេស នៅទីស្នាក់ការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួន ៩លើក
- រៀបចំកិច្ចប្រជុំក្រុមការងារគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃក្រសួងមុខងារសាធារណៈ ចំនួន ៣ លើក
- បានប្រជុំកែសម្រួលសមាសភាពក្រុមប្រឹក្សាបច្ចេកទេសរបស់ក្រសួងមុខងារសាធារណៈ ចំនួន ២ លើក
- ប្រជុំធ្វើផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ របស់ក្រសួងសម្រាប់ទិសដៅ ឆ្នាំ២០២០
- បានផ្សព្វផ្សាយខ្លីៗតាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងតាមបណ្តាអង្គភាពនានាក្រោមឱវាទក្រសួង ចំនួន ១៥ លើក

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

- បានជំរុញ និងធ្វើការណែនាំដល់អង្គភាពក្រោមឱវាទក្រសួង ដែលមានគេហទំព័រឱ្យផ្សព្វផ្សាយសារអប់រំជាប្រចាំទាំងបញ្ហាអេដស៍ គ្រឿងញៀន និងចរាចរ នៅលើគេហទំព័ររបស់ខ្លួន។
- បានផ្សព្វផ្សាយសារអប់រំជាប្រចាំពីបញ្ហាអេដស៍ ក្នុងគេហទំព័រ និងក្នុងព្រឹត្តិប័ត្រប្រចាំត្រីមាសរបស់ក្រសួង។
- បានបន្តការតាមដានផ្តល់សារអប់រំពីបញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ ដោយប្រើប្រាស់ប្រព័ន្ធលេខទូរស័ព្ទខ្លី៤ខ្ទង់។
- បានប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងចំនួន២លើក ស្តីពីយុទ្ធសាស្ត្រចូលរួមបញ្ចប់ជំងឺអេដស៍ និងទប់ស្កាត់ការប្រើប្រាស់ជួញដូរគ្រឿងញៀន និងបានរៀបចំសិក្ខាសាលាដែលអ្នកចូលរួមចំនួន៤០០នាក់។

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ ( ត )

UNAIDS

- ផ្ដល់ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគសម្រាប់កម្មវិធីការត្រួតពិនិត្យកម្មវិធីអេដស៍រួមគ្នា
- បានផ្ដល់ការគាំទ្របច្ចេកទេស និងការណែនាំជាយុទ្ធសាស្ត្រសម្រាប់ផែនការយុទ្ធសាស្ត្រជាតិ លើកទី៥ (២០១៩-២០២៣)
- បានគាំទ្របច្ចេកទេស និងការសម្របសម្រួលជាមួយ PEPFAR សម្រាប់ការអនុវត្ត Sustainability Index dashboard ឆ្នាំ២០១៩
- បានចូលរួមយ៉ាងសកម្មនៅក្នុង CCC និង CCC-OC និងបានរួមចំណែកដល់ដំណើរការផ្សេងៗដើម្បីធានាបាននូវវឌ្ឍនភាព និងសម្រេចបាននូវការអនុវត្តជំនួយដ៏ល្អប្រសើរបំផុត
- ក្រៅពីនេះការងារសំខាន់ៗមួយចំនួនទៀតដូចជា៖
  - NASA, GAM, AEM, PMTCT, PrEP etc.

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)




## លទ្ធផលនៃការធ្វើតេស្តឈាមទៅតាមក្រុមគោលដៅនីមួយៗនៃក្រុមប្រឈម

| ប្រភេទក្រុមគោលដៅ | ក្រុមគោលដៅបានជួប | ចំនួនបានធ្វើតេស្ត | ចំនួនប្រតិកម្មតេស្ត | ចំនួនតេស្តបញ្ជាក់លទ្ធផល HIV+ | % នៃលទ្ធផល HIV+ | ចំនួនចុះឈ្មោះទទួលសេវា Pre-ART /ART | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|
| ស្ត្រីបម្រើសេវាកម្សាន្ត | ២០,៣៩៩ | ៧,៨៤៦ | ៦ | ៥ | ០.១% | ៥ | ១ មិនទាន់តេស្តបញ្ជាក់ |
| ក្រុមបុរសរួមភេទជាមួយបុរស | ៩,៧៨៤ | ៤,៨២៥ | ៦៧ | ៦៤ | ១.៣% | ៦៤ | ៣ មិនទាន់តេស្តបញ្ជាក់ |
| អ្នកប្លែងភេទ | ២,៨៨២ | ១,៥៤៨ | ៦៦ | ៦៦ | ៤.៣% | ៦៦ | |
| **សរុប** | **៣៣,០៦៥** | **១៤,២១៩** | **១៣៩** | **១៣៥** | **០.៩%** | **១៣៥** | **៤ករណីមិនទាន់តេស្តបញ្ជាក់** |

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)




លទ្ធផលនៃការចែកស្រោមអនាម័យដល់ក្រុមគោលដៅប្រឈមមុខខ្ពស់

| ប្រភេទក្រុមគោលដៅ | ចំនួនក្រុមគោលដៅបានជួប | ចំនួនស្រោមអនាម័យបានចែក | ចំនួនទឹករំអិលបានចែក |
|---|---|---|---|
| ស្ត្រីបម្រើសេវាកម្សាន្ត | ២០,៣៩៩ | ២៥៧,៤០៩ | ៨០,២២៣ |
| ក្រុមបុរសរួមភេទជាមួយបុរស | ៩,៧៨៤ | ៩៣,៩៨៧ | ៩៣,៩៨៧ |
| អ្នកប្លែងភេទ | ២,៨៨២ | ២៧,៤២៣ | ២៧,៤២៣ |
| សរុប: | ៣៣,០៦៥ | ៣៧៨,៨១៩ | ២០១,៦៣៣ |

# ផែនទីគ្របដណ្ដប់សេវាបង្ការមេរោគអេដស៍តាមរយៈការចុះអប់រំផ្ទាល់នៅតាមសហគមន៍



# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)




អង្គការថែទាំសុខភាពគ្រួសារកម្ពុជា(រ៉ាក់)
REPRODUCTIVE HEALTH ASSOCIATION OF CAMBODIA (RHAC)

- លទ្ធផលនៃការគ្របដណ្តប់របស់អង្គការ រ៉ាក់ លើខេត្តចំនួន១០ នៅភាគខាងជើងមានដូចជា៖
  - ក្រុមនារីបម្រើសេវាកម្សាន្តសប្បាយចំនួន
  - ក្រុមបុរសស្រឡាញ់បុរស
  - ក្រុមប្លែងភេទ

| No | Output Indicator | Result Jul- Sep, 2019 | | | | Total KP | % compare to total KP |
|---|---|---|---|---|---|---|---|
| | | FEW | MSM | TG | Total | | |
| A | # of Key Population who were registered in RHAC M&E System | 1,036 | 412 | 62 | 1,510 | | |
| B | # of Key Population who received Health Education | 9,954 | 9,326 | 1,193 | 20,473 | 19,483 | 105% |
| C1a | # of Key Population who received condoms | 9,954 | 9,326 | 1,193 | 20,473 | 19,483 | 105% |
| C1b | # of Key Population who received lubricants | 3,712 | 9,198 | 1,185 | 14,095 | 10,243 | 137% |
| C2 | # of Key Population who were tested for HIV through finger prick | 4,112 | 4,050 | 526 | 8,688 | 19,483 | 44.5% |
| C3 | # of Key Population who have HIV reactive result through finger prick | 19 | 64 | 6 | 89 | | |
| C4 | # of Key Population who received HIV confirmatory test at health facility | 19 | 63 | 5 | 87 | | |
| C5 | # of Key Population who have HIV positive result (+) | 18 | 63 | 5 | 86 | | |
| | # of Key Population who have HIV negative result (-) | 1 | 0 | 0 | 1 | | |

# ២. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្ការការចម្លងមេរោគអេដស៍ (ត)

psi

នៅក្នុងត្រីមាសទី៣ (កក្កដា-កញ្ញា) អង្គការ PSI បានធ្វើការចែកចាយស្រោមអនាម័យបុរសទូទាំងប្រទេសបាន ចំនួនដូចខាងក្រោម ៖

| | កក្កដា | សីហា | កញ្ញា | សរុប |
|---|---|---|---|---|
| Total male condom | 852,294 | 148,284 | 907,194 | 1,773,772 |
| Sample | 8,280 | 1,152 | 33,984 | 43,416 |
| Total | 860,574 | 149,436 | 941,178 | 1,817,188 |

# ៣. វឌ្ឍនភាព និងសមិទ្ធផលនៃការថែទាំ និងព្យាបាល

## រូបភាពទី១: និន្នាការចំនួនទីកន្លែងផ្ដល់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ដែលបានទទួលសេវាពីឆ្នាំ២០០១ ដល់ត្រីមាសទី២ ឆ្នាំ ២០១៩



## រូបភាពទី២ : និន្នាការចំនួនអ្នកផ្ទុកមេរោគអេដស៍កុមារ និងមនុស្សពេញវ័យដែលបានទទួលសេវាព្យាបាល ដោយឱសថប្រឆាំងមេរោគអេដស៍ពីឆ្នាំ ២០១៤ ដល់ត្រីមាសទី៤ឆ្នាំ២០១៨




អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

# **រូបភាពទី៣** : និន្នាការនៃស្ត្រីពិនិត្យផ្ទៃពោះដឹងពីស្ថានភាពមេរោគអេដស៍ បានធ្វើតេស្ត និងទទួលលទ្ធផលពីឆ្នាំ ២០០៧-២០១៩



## **រូបភាពទី៤** : និន្នាការនៃស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីឆ្នាំ២០០៧-២០១៩



# ៤. ចន្លោះភាព និងសមិទ្ធផលនៃការកាត់បន្ថយផលប៉ះពាល់ និងការរើសអើង

បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយតំណាងខេត្តស្តីអំពីការកាត់បន្ថយមាក់ងាយ និងរើសអើងក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ធ្វើនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមាន សមាជិកមកពីខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តសៀមរាប រាជធានីភ្នំពេញ និងអង្គការដៃគូសរុប ចំនួន២៨នាក់។

សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវការអង្កេតសន្ទស្សន៍ការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍២.០ នៅប្រទេសកម្ពុជា នៅសណ្ឋាគារភ្នំពេញ។ សិក្ខាសាលានេះរៀបចំដោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការfhi360, Linkages, Population Council និងCPN+ និងទទួលការឧបត្ថម្ភពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) PEPFAR និង UNAIDS។

# ៥. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្កើនបរិយាកាសគាំទ្រការឆ្លើយតប មេរោគអេដស៍ និងជំងឺអេដស៍

- វគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី បរិយាកាសគាំទ្រច្បាប់ គោលនយោបាយ និងភារកិច្ចក្នុងការគាំទ្រការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ (សម្រាប់ថ្នាក់ស្រុក) ដែលបានរៀបចំនៅខេត្តសៀមរាប បាត់ដំបង បន្ទាយមានជ័យ និងខេត្តកំពត ដែលមានអ្នកចូលរួមទាំងអស់ប្រមាណ១៥០នាក់។ អ្នកចូលរួមជាតំណាងមកពី PAS, PAO, NGOs, police, ODs, អ្នកផ្តល់សេវាសុខភាព, និងការិយាល័យស្រុកពាក់ព័ន្ធ។






- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមដឹកនាំ កិច្ចប្រជុំក្រុមការងារ ស្តីពីទំនាក់ទំនងអំពើហិង្សាយេនឌ័រ និងមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈម នៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង ដោយមានការចូលរួមពីមន្ត្រីមកពីស្ថាប័នថ្នាក់ជាតិ មន្ទីរនានាក្នុងខេត្តបាត់ដំបង និងអង្គការសង្គមស៊ីវិល ចំនួន៤៣ រូប។

# ៥. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្កើនបរិយាកាសគាំទ្រការឆ្លើយតប មេរោគអេដស៍ និងជំងឺអេដស៍ (ត)

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ក្នុងគោលបំណងធ្វើបច្ចុប្បន្នភាពពីស្ថានភាពបុរសរួមភេទជាមួយបុរស និងស្រីស្រស់ ជាមួយអង្គការដៃគូសម្រាប់អនុវត្តសកម្មភាពក្នុងឆ្នាំ២០១៩។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសហការជាមួយអង្គការ FHI 360 ក្នុងការរៀបចំសេចក្តីណែនាំ  សម្រាប់ផ្តល់សេវាក្នុងការឆ្លើយតបនឹងហិង្សាទាក់ទងនឹងយេនឌ័រ សម្រាប់ប្រជាជនទូទៅ  និងក្រុមប្រឈមខ្ពស់ក្នុងខេត្តបាត់ដំបង  ដោយផ្តោតលើការរួមបញ្ចូលគ្នានៃសេវាមេរោគអេដស៍  ជំងឺអេដស៍ និងអំពើហិង្សានឹងយេនឌ័រ។





# ៥. វឌ្ឍនភាព និងសមិទ្ធផលនៃការបង្កើនបរិយាកាសគាំទ្រការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ (ត)

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំសិក្ខាសាលាស្តីពីការធ្វើសមាហរណកម្ម កម្មវិធីអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងវឌ្ឍនភាពនៃការជ្រើសរើសគ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានប័ណ្ណសមធម៌ ខេត្តបាត់ដំបង។ សិក្ខាសាលាមានការអញ្ជើញចូលរួមពីតំណាងក្រសួងផែនការ ប្រធានកម្មវិធីអេដស៍ខេត្ត មេឃុំ ចៅសង្កាត់ មកពី ៩ ខេត្ត ក្រុង ដែលមានសមាជិកសរុបចំនួន ៦០នាក់។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការ HP+ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការសិក្សាអំពីច្បាប់ និងបទ បញ្ញត្តិនៃការផ្តល់សេវាសុខាភិបាលនៃវិស័យឯកជនឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា។ គោលបំណងអង្គសិក្ខាសាលា គឺពិនិត្យមើលលើរបកគំហើញនៃការសិក្សា និងពិភាក្សាពីឧបសគ្គ និងឱកាសក្នុងការពង្រឹងការចូលរួមពីវិស័យឯកជនក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសក្នុងដំណាក់កាលឈានទៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥។

# ៦. វឌ្ឍនភាព និងសមិទ្ធផលនៃការតាមដាន និងវាយតម្លៃ

- បានរៀបចំផ្ញើទិន្នន័យទាក់ទងនឹងវឌ្ឍនភាពនៃការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ប្រចាំឆ្នាំ២០១៨ (GAM 2018 Report) និងទិន្នន័យពាក់កណ្ដាលអាណត្តិឆ្នាំ២០១៩ (Mid-2019 Report) ទៅតាមសូចនាករដែលអង្គការសហប្រជាជាតិកំណត់បានទាន់ពេលវេលា។
- បានបញ្ចប់របាយការណ៍ស្ដីពីការអង្កេតការចំណាយថវិកាលើការប្រយុទ្ធនឹងជំងឺអេដស៍ លើកទី ៦ សម្រាប់ឆ្នាំ ២០១៦-២០១៧ (NASA Report, 2016-2017)
- បានបញ្ចប់សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រជាតិពហុវិស័យឆ្លើយតបមេរោគអេដស៏ និងជំងឺអេដស៍ លើកទី៥ (២០១៩-២០២៣) ដែលមានយុទ្ធសាស្ត្រសំខាន់ៗដូចជា៖
    - បង្ការ ថែទាំ និងគាំទ្រ
    - បញ្ជ្រាបកម្មវិធីអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល និងក្រសួងដែលពាក់ព័ន្ធ
    - ពង្រឹកការគាំពារសង្គម និងបង្កើនបរិយាកាសគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះដើម្បីស្វែងរកសេវាសុខភាព សេវាច្បាប់ និងសេវាសង្គមផ្សេងៗ
    - បង្កើនថវិកាជាតិចំនួន៥០%លើកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ និងបែងចែកទៅដល់អង្គការសង្គមស៊ីវិល
- បានបញ្ចប់ការរៀបចំផែនការសកម្មភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០២០ សម្រាប់ថវិកាជាតិ






# ៧. សេចក្តីសន្និដ្ឋាន

1. យុទ្ធសាស្ត្រដឹកនាំ និងសម្របសម្រួល សម្រាប់ការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រព្រឹត្តទៅតាមផែនការ។
2. យុទ្ធសាស្ត្រថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ដោយឱសថប្រឆាំងនឹងមេរោគអេដស៍បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព ហើយដែលអាចរំពឹងថានឹងសម្រេចបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ ខាងមុខ។
3. យុទ្ធសាស្ត្រផ្តល់សេវាគាំទ្រសង្គមទៅដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ និងជនរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺអេដស៍គឺបានប្រព្រឹត្តទៅជាប្រចាំ នឹងមានវិសាលភាពធំជាងមុន។
4. យុទ្ធសាស្ត្រកាត់បន្ថយការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍នៅកម្ពុជានៅតែបង្ហាញនូវសញ្ញាវិជ្ជមានក្នុងការឈានទៅបញ្ចប់ការរើសអើងទាំងស្រុងទៅតាមគោលដៅឆ្នាំ២០២៥ ព្រោះគ្មានរបាយការណ៍ណាមួយស្តីពីការរើសអើង និងដោយឡែកលទ្ធផលសិក្សាពីសន្ទស្សន៍នៃការមាក់ងាយ និងរើសអើងលើអ្នកផ្ទុកមេរោគអេដស៍បានបង្ហាញការថយចុះបើធៀបនឹងការសិក្សាលើកមុន។

# ៧. សេចក្តីសន្និដ្ឋាន (ត)

5. យុទ្ធសាស្ត្របង្ការលើក្រុមគោលដៅដែលប្រឈមខ្ពស់ បានប្រព្រឹត្តទៅតាមផែនការដោយអាចគ្របដណ្តប់ស្ទើរតែគ្រប់ខេត្តគោលដៅ និងក្រុមគោលដៅទាំងអស់តាមរយៈកម្មវិធីរបស់មូលនិធិសកល ដែលអនុវត្តដោយអង្គការ KHANA អង្គការ RHAC។ល។
6. ទន្ទឹមនឹងរបាយការណ៍ដែលទទួលបានពីសមាជិក អ.ជ.ប.ជ.អ មួយចំនួនធំ ក៏នៅមានសមាជិក អ.ជ.ប.ជ.អ មួយចំនួនតូច មិនបានផ្តល់របាយការណ៍មកអគ្គលេខាធិការដ្ឋានបានទាន់ពេលវេលា ឬមិនគ្រប់ជ្រុងជ្រោយដែរ ដែលអាចប៉ះពាល់ទៅដល់គុណភាពនៃការរៀបចំចងក្រងរបាយការណ៍ប្រចាំឆ្នាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
7. ជារួមកម្ពុជានៅតែមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយអាច ទប់ស្កាត់ការរាលដាលលមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបន្តធ្លាក់ចុះជាប្រចាំ ហើយអាចសង្ឃឹមថានឹងសម្រេចបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ខាងមុខ។

# ៨. សេចក្តីថ្លែងអំណរគុណ

សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

1. គណៈកម្មាធិការ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង និងរាជធានី ខេត្តដែលបានផ្តល់នូវរបាយការណ៍ជូនមកអគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ បានទាន់ពេលវេលា។
2. អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល។ល។ ដែលបានផ្តល់របាយការណ៍ជូនមកអគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ បានទាន់ពេលវេលា។
3. អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ជាពិសេសនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ ដែលបានរៀបចំធ្វើបទបង្ហាញនូវរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩នេះ។

# ៩. ការប្រៀបធៀបរបាយការណ៍

តារាងប្រៀបធៀបរបាយការណ៍ដែលបានទទួលតាម ក្រសួង រាជធានី ខេត្ត នៅក្នុងកិច្ចប្រជុំពេញអង្គលើកទី១ និងលើកទី២

| កិច្ចប្រជុំពេញអង្គលើកទី១ | | កិច្ចប្រជុំពេញអង្គលើកទី២ | |
|---|---|---|---|
| ក្រសួង-រាជធានី | ខេត្ត | ក្រសួង-រាជធានី | ខេត្ត |
| 17 | 20 | 24 | 25 |
| | | | |

## ឧបសម្ព័ន្ធទី១ : តារាងចំនួនក្រសួងដែលបានផ្ដល់របាយការណ៍មកអ.ជ.ប.ជ.អ

| | ក្រសួង | អ៊ីមែល | តេឡេក្រាម | ឯកសារផ្លូវកា |
|---|---|---|---|---|
| ១ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៣/១០/១៩ | | ៣/១០/១៩ |
| ២ | ក្រសួងព័ត៌មាន | ១៧/០៩/១៩ | | ១៧/០៩/១៩ |
| ៣ | ក្រសួងធនធានទឹក និងឧតុនិយម | ១៧/០៩/១៩ | | ២៣/០៩/១៩ |
| ៤ | ក្រសួងការពារជាតិ | ១/១០/១៩ | | ១/១០/១៩ |
| ៥ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១/១០/១៩ | | ២១/១០/១៩ |
| ៦ | មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក (សុខាភិបាល) | | ២/១០/១៩ | ២/១០/១៩ |
| ៧ | ក្រសួងអប់រំ យុវជន និងកីឡា | ៣/១០/១៩ | | ១០/១០/១៩ |
| ៨ | អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | ៤/១០/១៩ | | ៤/១០/១៩ |
| ៩ | ក្រសួងបរិស្ថាន | ៤/១០/១៩ | | |
| ១០ | ក្រសួងកិច្ចការនារី | ៤/១០/១៩ | | |
| ១១ | កាកបាទក្រហម | ៤/១០/១៩ | | |
| ១២ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | | ៦/១០/១៩ |
| ១៣ | ក្រសួងសាធារណការ និងដឹកជញ្ជូន | | ៦/១០/១៩ | |
| ១៤ | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៤/១០/១៩ | | ៨/១០/១៩ |

## ឧបសម្ព័ន្ធទី១: តារាងចំនួនក្រសួងដែលបានផ្តល់របាយការណ៍មកអ.ជ.ប.ជ.អ

| | ក្រសួង | អ៊ីមែល | តេឡេក្រាម | ឯកសារផ្លូវការ |
|---|---|---|---|---|
| ១៥ | ក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ | | ៧/១០/១៩ | ១៨/១០/១៩ |
| ១៦ | ក្រសួងទេសចរណ៍ | | ៦/១០/១៩ | |
| ១៧ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | ៧/១០/១៩ | | |
| ១៨ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | ៧/១០/១៩ | ១៤/១០/១៩ |
| ១៩ | ក្រសួងអភិវឌ្ឍន៍ជនបទ | | | ៨/១០/១៩ |
| ២០ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | ៧/១០/១៩ | | |
| ២១ | ក្រសួងរ៉ែ និងថាមពល | ១៧/១០/១៩ | | |
| ២២ | ក្រសួងផែនការ | ១៨/១០/១៩ | | ១៨/១០/១៩ |
| ២៣ | ក្រសួងធម្មការ និងសាសនា | | | ២២/១០/១៩ |
| ២៤ | ក្រសួងមុខងារសាធារណៈ | | ៣១/១០/១៩ | |
| | | | | |

## ឧបសម្ព័ន្ធទី២: តារាងចំនួនខេត្តដែលបានផ្តល់របាយការណ៍មក អ.ជ.ប.ជ.អ

| ល.រ | ខេត្ត | អ៊ីមែល | តេឡេក្រាម | ឯកសារផ្លូវការ |
|---|---|---|---|---|
| ១ | ខេត្តកណ្តាល (ត្រីមាស.ទី២ ៣ ) | ៣១/០៧/១៩ . ៧/១០/១៩ | | |
| ២ | ខេត្តរតនគិរី (ត្រីមាស. ទី២) | ១៤/០៨/១៩ | | |
| ៣ | ខេត្តក្រចេះ (ត្រីមាស.ទី២ ៣ ) | ១៦/០៨/១៩ | | ១៦/០៨/១៩ |
| ៤ | ខេត្តកំពង់ឆ្នាំង (ត្រីមាស. ទី២) | ២៣/០៨/១៩ | | |
| ៥ | ខេត្តព្រៃវែង (ត្រីមាស. ទី២) | ២៦/០៨/១៩ | | |
| ៦ | ខេត្តបន្ទាយមានជ័យ (ត្រីមាស.ទី២) | ២៦/០៨/១៩ | | |
| ៧ | ឧត្តរមានជ័យ (ត្រីមាស. ទី២ ) | ២៩/០៨/១៩ | | |
| ៨ | ខេត្តកំពង់ស្ពឺ (ត្រីមាសទី ៣) | | ៧/១០/១៩ | |
| ៩ | ខេត្តព្រះសីហនុ (ត្រីមាសទី ៣) | ៣/១០/១៩ | | |
| ១០ | ខេត្តព្រះវិហារ (ត្រីមាសទី ៣) | ៤/១០/១៩ | | |
| ១១ | ខេត្តកែប (ត្រីមាសទី ៣) | ៤/១០/១៩ | | |
| ១២ | ខេត្តមណ្ឌលគិរី (ត្រីមាសទី ៣) | ៤/១០/១៩ | | |
| ១៣ | ខេត្តកោះកុង (ត្រីមាសទី ៣) | ៧/១០/១៩ | | |
| ១៤ | ខេត្តកំពត (ត្រីមាសទី ៣) | ៧/១០/១៩ | | |
| ១៥ | ខេត្តកំពង់ចាម (ត្រីមាស. ទី២ ) | ៣/១០/១៩ | | |

## ឧបសម្ព័ន្ធទី២ : តារាងចំនួនខេត្តដែលបានផ្តល់របាយការណ៍មក អ.ជ.ប.ជ.អ

| ល.រ | ខេត្ត | អីម៉ែល | តេឡេក្រាម | ឯកសារផ្លូវកា |
|---|---|---|---|---|
| ១៦ | ខេត្តពោធិ៍សាត់ (ត្រីមាស. ទី២ ) | ២/១០/១៩ | | |
| ១៧ | ខេត្តកំពង់ធំ (ត្រីមាសទី ៣) | ៧/១០/១៩ | | |
| ១៨ | ខេត្តត្បូងឃ្មុំ (ត្រីមាសទី ៣) | ៧/១០/១៩ | | |
| ១៩ | ខេត្តប៉ៃលិន (ត្រីមាសទី ៣) | | ៧/១០/១៩ | |
| ២០ | ខេត្តស្វាយរៀង (ត្រីមាសទី ៣) | ៧/១០/១៩ | | |
| ២១ | ខេត្តបាត់ដំបង (ត្រីមាសទី ២ ៣) | ១៥/១០/១៩ | | |
| ២២ | មន្ទីរសុខាភិបាលរាជធានីភ្នំពេញ(ត្រីមាសទី៣) | ១៧/១០/១៩ | | ១៨/១០/១៩ |
| ២៣ | ខេត្តតាកែវ (ត្រីមាសទី ២ ៣) | | ២២/១០/១៩ | |
| ២៤ | ខេត្តសៀមរាប (ឆមាសទី៣) | ២៤/១០/១៩ | | |
| ២៥ | ខេត្តស្ទឹងត្រែង | | ២៥/១០/១៩ | |

# ឧបសម្ព័ន្ធ៣ : តារាងចំនួនខេត្តដែលបានផ្តល់របាយការណ៍មក អ.ជ.ប.ជ.អ

| ល.រ | អង្គការ | អីមែល | តេឡេក្រាម | ឯកសារផ្លូវកា |
|---|---|---|---|---|
| ១ | អង្គការ RHAC | ៧/១០/១៩ | | |
| ២ | អង្គការ KHANA | ១៧/១០/១៩ | | |
| ៣ | អង្គការ UNAIDS | ២៤/១០/១៩ | | |
| ៤ | អង្គការ PSI | ៣០/១០/១៩ | | |
| | | | | |

# ក្រសួងដែលមិនបានផ្ញើរបាយការណ៍

1. ទីស្ដីការគណៈរដ្ឋមន្ត្រី
2. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
3. ក្រសួងពាណិជ្ជកម្ម
4. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
5. ក្រសួងយុត្តិធម៌
6. ក្រសួងមហាផ្ទៃ
7. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
8. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល